**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពត**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ : ...០១៤.......គល.កព២០១៧


ធានាពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ


# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការអញ្ជើញចូលរួមដេញថ្លៃ
## ការងារដាំបង្គោលភ្លើង និងតបណ្ដាញចំនួន៣៩បង្គោល ចាប់ពីរង្វង់មូលធុរេន រហូតដល់ស្តុបភូមិតាអេង ស្ថិតក្នុងភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត

ខេត្តកំពតសូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស(គិតទាំងសហគ្រាសឯកត្តបុគ្គល)ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថាខេត្តកំពតនឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារដាំបង្គោលភ្លើង និងតបណ្ដាញចំនួន៣៩បង្គោល ចាប់ពីរង្វង់មូលធុរេនរហូតដល់ស្តុបភូមិតាអេង ស្ថិតក្នុងភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត ។

ខេត្តកំពតបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ។ ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មខេត្តកំពតដែលមានអាសយដ្ឋាននៅសាលាខេត្ត (អគារចាស់ជាន់ទី១) ចាប់ពី ថ្ងៃទី..២០....ខែ..តុលា.....ឆ្នាំ២០១៧ តទៅរៀងរាល់ម៉ោងធ្វើការ ។

ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី....០៧.....ខែ..វិច្ឆិកា.....ឆ្នាំ២០១៧ វេលាម៉ោង....០៩:០០នាទីព្រឹក.។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាសយដ្ឋានខាងលើវេលាម៉ោង០៩:០០នាទីព្រឹក ថ្ងៃទី..០៧.....ខែ..វិច្ឆិកា........ ឆ្នាំ២០១៧។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃសូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃនិងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

ធ្វើនៅកំពត ថ្ងៃទី ..០៣...... ខែ ..តុលា.... ឆ្នាំ២០១៧

**ប្រធានគណៈកម្មាធិការលទ្ធកម្មខេត្តកំពត**

**ចាន់ ចេស្តា**

**ចម្លងជូន ៖**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ